២–ព្រះគ្រូ បរិត្ត **កោសល** បរិច្ចាគប្រាក់ ៣.៦០០$ US

៣–លោក **ស៊ុម ឈិន** អ្នកស្រី **ឡឹ ទី** បរិច្ចាគប្រាក់ ៣.៥០០$ US

៤–អ្នកស្រី **ម៉ែន ឡាក់** បរិច្ចាគប្រាក់ ៣.៤៨១$ US

៥–លោក **ម៉ុន គង់** អ្នកស្រី **ហេង ស៊ី** បរិច្ចាគ ៣.០៥០$ US

៦–លោក **ឈុំ ហ៊ុន** អ្នកស្រី **ម៉ុ កែវ** បរិច្ចាគប្រាក់ ១.៣០០$ US

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា និង អភិបាលខេត្ត បន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ដលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

## ២ - សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

### សេចក្ដីសំរេចលេខ ១៨ សសរ
### ស្ដីពីការបង្កើតគណៈកម្មការពិសេសសំរាប់ ពិនិត្យបញ្ជីហិរញ្ញវត្ថុ របស់ធនាគារកណ្ដាល
### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ចុះ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស.រកម ០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ .
- យោងតាមសំណើរបស់ ឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការពិសេសមួយ សំរាប់ត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៣-តំណាងអធិការកិច្ចរាជរដ្ឋាភិបាល | សមាជិក. |

**ប្រការ ២ :** គណៈកម្មការពិសេសនេះមាននាទីជាស្នងការគណនី និង មានភារកិច្ចធ្វើរបាយការណ៍ប្រចាំឆ្នាំពីរប្រភេទ គឺ :

-របាយការណ៍ទូទៅ

-របាយការណ៍ពិសេស

**ប្រការ ៣ :** របាយការណ៍ទូទៅ ជារបាយការណ៍ស្តីអំពីលទ្ធផលត្រួតពិនិត្យការចុះបញ្ជីក្នុងសៀវភៅត្រឹមត្រូវ ឬ មិនត្រឹមត្រូវតាមខ្ទង់គណនី នៃធនាគារកណ្តាល ។

**ប្រការ ៤ :** របាយការណ៍ពិសេស ជាសេចក្តីអត្ថាធិប្បាយលើរាល់កិច្ចការសន្យារវាងធនាគារកណ្តាល និងស្ថាប័នធនាគារនានា ឬ និង ស្ថាប័នហិរញ្ញវត្ថុកណ្តាល ឬ ថ្នាក់ដឹកនាំធនាគារកណ្តាលមានភាគហ៊ុន ។

**ប្រការ ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និង សាមីខ្លួនក្នុងប្រការ

១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៦

## សេចក្តីសំរេចលេខ ១៩ សសរ

## ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- ផ្អែកតាមការចាំបាច់ ។

## សំរេច

**ប្រការ ១** : ប្រគល់ភារកិច្ចជូនឯកឧត្តម **ស៊ុំ ម៉ាន់ិត** រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីស្តីទី ក្រសួងផែនការ ចាប់ពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃ ឯកឧត្តម **ជា ចាន់តូ** ត្រឡប់មកពីបំពេញបេសកកម្មនៅឯបរទេសវិញ ។

**ប្រការ ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង